# ក្រុមប្រឹក្សាអាជ្ញាកណ្តាល

# THE ARBITRATION COUNCIL

## និរន្តរភាព



ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយរវាង មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាមួយធនាគារពិភពលោក និង រាជរដ្ឋាភិបាលកម្ពុជា

ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានគោលដៅរក្សាវត្តមានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាជានិរន្តរ៍។ ក្រុមប្រឹក្សានេះមិនមែនជាគម្រោងការងារ ឬ កម្មវិធីបណ្តោះអាសន្នទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នជាតិឯករាជ្យមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ របស់ប្រទេសកម្ពុជាដោយមានសមាសភាពអាជ្ញាកណ្តាលកម្ពុជា ហើយក្រុមប្រឹក្សានេះបានក្លាយទៅជាផ្នែកដ៏សំខាន់មួយនៃវិស័យទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា។ ជំនួយក្នុងដំណាក់កាលដំបូងដែលអង្គការពលកម្មអន្តរជាតិបានផ្តល់មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានផ្ទេរទាំងស្រុងមកឱ្យមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយគ្រប់គ្រងដោយបុគ្គលិកកម្ពុជា ដែលទទួលភារកិច្ចគាំទ្រ និង សម្របសម្រួលការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បន្តរក្សាទំនាក់ទំនងជាមួយភាគីដែលពាក់ព័ន្ធនានា ដូចជាប្រជាពលរដ្ឋសហជីព អ្នកជំនួញ រដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ អ្នកបណ្តុះបណ្តាល និង ទីប្រឹក្សាផ្សេងៗ ព្រោះថាការគាំទ្រ សុឆន្ទៈ និង ការចូលរួមយ៉ាងសកម្មពីសំណាក់ភាគីដែល ពាក់ព័ន្ធទាំងអស់នេះមានសារៈសំខាន់ណាស់ចំពោះជោគជ័យជានិរន្តរ៍របស់ក្រុមប្រឹក្សាអាជ្ញា កណ្តាល។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល កំពុងតែសហការយ៉ាងសកម្មជាមួយរដ្ឋាភិបាល និង ធនាគារពិភពលោកនៅក្រោមគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងបន្តអនុវត្តបេសកម្មរបស់ខ្លួន និង ធានានូវនិរន្តរ៍ភាពសមិទ្ធិផលរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ចំពោះផែនការសម្រាប់អនាគត ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្រោងពង្រីកវិសាលភាពនៃដៃគូការងារ និងកម្មវិធីផ្សព្វផ្សាយរបស់ខ្លួន អនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ និង ទំនាក់ទំនងក្រុមគោលដៅ រួមមានការបង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រមទាំងបង្កើនសមត្ថភាពផ្នែកស្ថាប័នដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការបំពេញសកម្មភាពស្នូលរបស់ខ្លួនក្នុងការដោះស្រាយវិវាទការងារ។

## ការផ្តល់ជំនួយហិរញ្ញវត្ថុ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ផ្តល់សេវាផ្សះផ្សា និង អាជ្ញាកណ្តាលដល់ភាគីដោយឥតគិតថ្លៃ ដោយពឹងផ្អែកទៅលើប្រភពជំនួយហិរញ្ញវត្ថុពីម្ចាស់ជំនួយអន្តរជាតិនានា។ ចំពោះផែនការទូទៅ ដើម្បីរក្សានិរន្តរ៍ភាពរបស់ស្ថាប័ន ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងព្យាយាមស្វែងរកការឧបត្ថម្ភភាគទានឱ្យកាន់តែច្រើនឡើង ពីសំណាក់ភាគីដែលមានប្រយោជន៍ពាក់ព័ន្ធក្នុងវិស័យការងារ និង ទំនាក់ទំនងវិជ្ជាជីវៈ។

**ម្ចាស់ជំនួយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនាពេលបច្ចុប្បន្នរួមមាន:**

- ធនាគារពិភពលោក/រាជរដ្ឋាភិបាលកម្ពុជា
- អង្គការពលកម្មអន្តរជាតិ (ILO)
- ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID)
- ទីភ្នាក់ងារនូវែលហ្សេឡង់ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (NZAid)
- មូលនិធិលីវ៉ាយស្ត្រោស (Levi Strauss Foundation)

## សម្រាប់ព័ត៌មានបន្ថែម


**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

- លេខ ៧២ ផ្លូវ ៥៩២ (កែងផ្លូវ ៣២៧) សង្កាត់ បឹងកក់២, ខ័ណ្ឌ ទួលគោក, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា (ចាប់ពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០) ។
- ទូរស័ព្ទលេខ: (៨៥៥) +២៣-២២៣-៥០៦
- ទូរសារលេខ: (៨៥៥) +២៣-២២០-៧៩៣។
- អ៊ីម៉ែល: info@arbitrationcouncil.org
- វិបសាយ: www.arbitrationcouncil.org

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL



# នីតិវិធីដោះស្រាយវិវាទការងាររួម នៅកម្ពុជា

*"ការកែទម្រង់មួយក្នុងចំណោមការកែទម្រង់ដ៏ជោគជ័យនានា របស់កម្ពុជា គឺក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាមជ្ឈមណ្ឌលមជ្ឈត្តការផ្នែក ពលកម្មសំរាប់ដោះស្រាយវិវាទពលកម្ម យ៉ាងមានប្រសិទ្ធិភាព តាំងពីពេលដែលគេ បង្កើតឡើងនៅឆ្នាំ ២០០៣។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្ហាញថាគេអាចបង្កើតស្ថាប័នដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជា ដែលមានគុណភាពខ្ពស់មានប្រសិទ្ធិភាព និងមិនមានអំពើពុករលួយ..."*

ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្ម លេខ១៤ ២០០៧ អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)

## ស្ថាប័នគ្មានពីរ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នតែមួយគត់ នៅប្រទេសកម្ពុជាដែល ដោះស្រាយបណ្តឹងទាមទារទាក់ទងនឹងការរំលោភសិទ្ធិការងារ និង វិវាទនៅកន្លែងធ្វើការតាមរយៈការចូលរួមដោយផ្ទាល់ ពីសំណាក់កម្មករ និយោជិត និង និយោជកតាមរយៈការធ្វើអាជ្ញាកណ្តាល។

## បង្កើតឡើងក្រោមការជួយឧបត្ថមពីអង្គការពលកម្មអន្តរជាតិដោយមានការគាំទ្រពីភាគីដែលពាក់ព័ន្ធ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានបង្កើតក្រោមការជួយឧបត្ថមពីអង្គការពលកម្មអន្តរជាតិ ដោយសហប្រតិបត្តិការជាមួយក្រសួងការងារ និយោជក និង សហជីពកម្មករ។ ក្រុមប្រឹក្សានេះបានដើរតួនាទីជាសាលាជំនុំជម្រះក្តីមួយរបស់កម្ពុជាដែលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយបានទទួលការទុកចិត្តពីមហាជនដោយសារតែភាពស្អាតស្អំ និង សមត្ថភាពពិតប្រាកដរបស់ខ្លួនក្នុងការដោះស្រាយវិវាទការងារដោយសន្តិវិធី និង ប្រកបដោយប្រសិទ្ធិភាព។

## ជួយដល់កម្មករនិយោជិត និង និយោជក

កម្មករនិយោជិត និង និយោជកទទួលការជួយជ្រោមជ្រែងដោយផ្ទាល់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការដោះស្រាយបញ្ហាវិវាទការងារ។ អាជ្ញាកណ្តាលប្រើការផ្សះផ្សា និង ការធ្វើអាជ្ញាកណ្តាលដើម្បីជួយដល់ភាគីដោះស្រាយវិវាទធានាល័ក្ខខ័ណ្ឌការងារដែលមានសុវត្ថិភាព និង ប្រកបដោយផលិតភាព ដែលធ្វើឱ្យកម្មករនិយោជិត ព្រមទាំងសហគ្រាស អាចត្រលប់ទៅធ្វើការ និង ដំណើរការជាប្រក្រតី។

## ជួយដល់សេដ្ឋកិច្ចជាតិ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចូលរួមចំណែកជម្រុញសេដ្ឋកិច្ចជាតិ និងជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសក្រីក្រ បំផុតនៅក្នុងពិភពលោក ដោយអនុវត្តគោលការណ៍នៃភាពត្រឹមត្រូវ និង យុត្តិធម៌។ ក្រុមប្រឹក្សានេះដោះស្រាយ ដោយផ្ទាល់ជាមួយជម្លោះដែលអាចបង្កឱ្យមានកូដកម្ម អូសបន្លាយ និង ខាតបង់ចំណូល ហើយថែមទាំងអាចបង្កឱ្យមានអំពើហឹង្សាទៀតផង ប្រសិនបើជម្លោះទាំងនេះមិនត្រូវបានដោះស្រាយទេនោះ។ ក្រុមប្រឹក្សានេះដោះស្រាយវិវាទយ៉ាងឆាប់រហ័ស និងមានតម្លាភាព ដោយផ្អែកលើច្បាប់និងបទដ្ឋានអន្តរជាតិ។ ការងារដោះស្រាយនេះសំដៅធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគទុន និង កំណើនសេដ្ឋកិច្ច លើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈល្អ និងការងារសមរម្យ ព្រមទាំងជម្រុញការអភិវឌ្ឍសង្គមនៅកម្ពុជា។

## ស្ថាប័នគំរូ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺជាស្ថាប័នគំរូក្នុងការដោះស្រាយវិវាទ ហើយក៏ជាស្ថាប័នជាតិឯករាជ្យមួយទទួលខុសត្រូវផ្តល់យុត្តិធម៌។ ក្រុមប្រឹក្សានេះមានសមត្ថភាពពិតប្រាកដក្នុងការបំពេញតួនាទីដ៏សំខាន់ជួយជម្រុញឱ្យមានអភិបាលកិច្ចល្អនិងពង្រឹងនីតិរដ្ឋនៅកម្ពុជា។

លេខ ៧២ ផ្លូវ ៥៩២ (កែងផ្លូវ ៣២៧) សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា (ចាប់ពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០)
ទូរស័ព្ទលេខៈ (៨៥៥) +២៣-២២៣-៥០៦ ទូរសារលេខៈ (៨៥៥) +២៣-២២០-៧៩៣។ • Email: info@arbitrationcouncil.org • Web: www.arbitrationcouncil.org

# ក្រុមប្រឹក្សាអាជ្ញាកណ្តាល
# THE ARBITRATION COUNCIL

## ប្រវត្តិ និង និដ្ឋភាពទូទៅ




រចនាសម្ព័ន្ធស្ថាប័ននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នជាតិឯករាជ្យមួយ ដែលមានមុខងារ ដោះស្រាយវិវាទការងារ។ ក្នុងនាមជាស្ថាប័នដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧) ក្រុមប្រឹក្សានេះធ្វើប្រតិបត្តិការក្រោមកិច្ចសហការជាមួយសង្គមស៊ីវិល និងរដ្ឋាភិបាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបង្កើតឡើងនៅឆ្នាំ ២០០៣ ដោយមានការជួយឧបត្ថមពីអង្គការពលកម្មអន្តរជាតិ ក្រោមកិច្ចសហការជាមួយដៃគូត្រីភាគីរួមមាន ក្រសួងការងារ សមាគមនិយោជក និង សហជីពកម្មករនិយោជិត។

*មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល* ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៤ ដើម្បីជួយរក្សានិរន្តរភាពការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ មូលនិធិនេះ ត្រូវបានបង្កើតឡើងក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដើម្បីផ្តល់ការគ្រាំទ្រផ្នែកបច្ចេកទេសផ្នែកច្បាប់ និងការគ្រប់គ្រងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សា អាជ្ញាកណ្តាល។

ជាមួយគ្នានេះផងដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏ទទួលការគាំទ្រផ្នែកក្រឡាបញ្ជី និងការគ្រប់គ្រងសំណុំរឿង ពី*លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល* ដែលមានបុគ្គលិកជាមន្ត្រីដែលចាត់តាំងដោយក្រសួងការងារ។

## ការដោះស្រាយវិវាទការងារ



ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោះស្រាយវិវាទ ដោយឯករាជ្យ មិនលំអៀង និងមិនស្ថិតក្រោមឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅឡើយ។ ព្រមជាមួយគ្នានេះដែរ ការចូលរួមចំណែកយ៉ាងសកម្មពីភាគី ដែលពាក់ព័ន្ធមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ការងាររបស់ក្រុមប្រឹក្សានេះ។ នៅក្នុងសំណុំរឿងវិវាទការងារនីមួយៗ ភាគីទាំងសងខាង គឺជាអ្នកជ្រើសរើសអាជ្ញាណ្តាលពីររូបក្នុងចំណោមអាជ្ញាកណ្តាលទាំងបីរូបនៅក្នុងក្រុមអាជ្ញាកណ្តាលដើម្បី សម្រេចសេចក្តីលើសំណុំរឿងរបស់ពួកគាត់។

នៅក្នុងសវនាការ ក្រុមអាជ្ញាកណ្តាលតែង លើកទឹកចិត្តកម្មករនិយោជិត និង និយោជក ឱ្យស្វែងរកគោលជំហរ និង ផលប្រយោជន៍រួមដើម្បីធ្វើយ៉ាងណាដោះស្រាយជម្លោះរបស់ខ្លួនតាមរយៈការព្រមព្រៀងគ្នា។ ប្រសិនបើភាគីមិនអាចឈានដល់កិច្ចព្រមព្រៀង ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងដោះស្រាយសំណុំរឿងនោះតាមរយៈការកាត់សេចក្តីតាមនីតិវិធីអាជ្ញាកណ្តាលជាផ្លូវការ។ ភាគីទាំងសងខាងមានឱកាសបង្ហាញការទាមទារ និងការយល់ឃើញរបស់ខ្លួន ព្រមទាំងផ្តល់ជូននូវឯកសារសាក្សី និង ភស្តុតាងដទៃទៀត ដើម្បីគាំទ្រគោលជំហររបស់ខ្លួន។

ក្រុមអាជ្ញាកណ្តាលចេញសេចក្តីសម្រេច ទៅលើសំណុំរឿងរបស់ភាគី ក្នុងរយៈពេល ១៥ថ្ងៃ តាមរយៈសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលមានលក្ខណៈលំអិត និងរៀបរាប់យ៉ាងក្បោះក្បាយ។ សេចក្តីបង្គាប់អាជ្ញាកណ្តាល គូសបញ្ជាក់អំពីមូលដ្ឋាននៃសេចក្តីសម្រេចនីមួយៗ ដោយប្រើប្រាស់ហេតុផលផ្លូវច្បាប់ដើម្បី យកមកដោះស្រាយចំណុចបញ្ហានៅក្នុងសំណុំរឿងនីមួយៗ។ ចំណុចវិវាទដែលភាគីនាំមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ទាក់ទងនឹងចំណុច វិវាទផ្សេងៗគ្នាជាច្រើន ដូចជាបញ្ហាសិទ្ធិសម្រាកលំហែមាតុភាព សេរីភាពបង្កើតសមាគម កិច្ចសន្យាការងារប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗ ការងារបន្ថែមម៉ោងសុវត្ថិភាព និង សុខុមាលភាពនៅកន្លែងធ្វើការ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភាពជាក់លាក់ និង ផ្តល់ជូនភាគីនូវដំណោះស្រាយផ្អែកលើភាពជាក់ស្តែង ដើម្បីដោះស្រាយវិវាទ ហើយឱ្យភាគីបន្តប្រកបការងារវិញតាមប្រក្រតី។ សេចក្តីបង្គាប់ទាំងអស់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានផ្សព្វផ្សាយជាសាធារណៈ ទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស នៅលើគេហទំព័ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង នៅក្នុងសៀវភៅកម្រងសេចក្តីបញ្ហា និង សេចក្តីបង្គាប់អាជ្ញាកណ្តាល។

ចាប់តាំងពីពេលបង្កើតមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងជាង ៨០០ សំណុំរឿងពាក់ព័ន្ធជាមួយសហគ្រាស ដែលជួលកម្មករនិយោជិតសរុបជាង ៣៦០.០០០ នាក់។ កម្មករនិយោជិតទាំងនេះភាគច្រើនជាស្ត្រីមកពីតំបន់ជនបទដែលប្រាក់កម្រៃ បានមកពីការងាររបស់ពួកគាត់ មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះក្រុមគ្រួសារពួកគាត់។




១) សម្រាប់ឆ្នាំ២០០៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចាប់ផ្តើមទទួលសំណុំរឿងពីខែឧសភា

២) តួលេខតាមការប៉ាន់ស្មានសម្រាប់ឆ្នាំ ២០០៩



# ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

# THE ARBITRATION COUNCIL

## សកម្មភាព និង ជោគជ័យ សំខាន់ៗ



**ដោះស្រាយវិវាទការងារ :** ជាទូទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានដោះស្រាយដោយជោគជ័យ នូវសំណុំរឿងប្រហែល ៧0% ក្នុងចំណោមសំណុំរឿងទាំងអស់ដែលខ្លួនទទួលបាន។

- ***ឯករាជ្យភាព :*** ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងគ្មានការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ។
- ***ប្រជាធិបតេយ្យ :*** ភាគីវិវាទជាអ្នកជ្រើសរើសអាជ្ញាកណ្ដាល ហើយអាចបញ្ចេញយោបល់ និងទស្សនៈរបស់ខ្លួននៅក្នុងដំណើរការ និងនៅក្នុងសេចក្ដីសម្រេច ដែលនឹងប៉ះពាល់ទៅដល់ការងារ និងជីវភាពរស់នៅរបស់ពួកគេ។
- ***ទំនុកចិត្ត :*** អាជ្ញាកណ្ដាលទទួលបានការជឿទុកចិត្ត ដោយសារតែភាពស្អាតស្អំ និង ជំនាញវិជ្ជាជីវៈរបស់ពួកគេ។
- ***ភាពឆាប់រហ័ស :*** សវនាការ និងសេចក្ដីសម្រេចនៅក្នុងសំណុំរឿងនីមួយៗ ត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ។
- ***តម្លាភាព :*** ហេតុផល និង មូលដ្ឋាននៃសេចក្ដីសម្រេចត្រូវបានសរសេរយ៉ាងក្បោះក្បាយជាលាយលក្ខណ៍អក្សរ នៅក្នុងសេចក្ដីបង្គាប់ដែលត្រូវបានបោះពុម្ពផ្សាយ ជាសាធារណៈ។
- ***ប្រសិទ្ធិភាព :*** វិវាទត្រូវបានដោះស្រាយ ហើយកម្មករនិយោជិត និងអាជីវកម្ម អាចត្រលប់ទៅប្រកបការងារវិញ។

### ពង្រឹងសមត្ថភាពរបស់ដៃគូ :

វគ្គបណ្ដុះបណ្ដាល ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងរបស់ភាគីដែលពាក់ព័ន្ធអំពីសិទ្ធិ និងការទទួលខុសត្រូវផ្នែកការងារបង្កើតជំនាញដើម្បីបង្ការ និងដោះស្រាយវិវាទការងារ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅកន្លែងធ្វើការ។

### កសាងភាពជាដៃគូ :

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលប្រឡូកក្នុងការងារសម្ព័ន្ធភាពពហុវិស័យ សន្ទនាមតិរវាងស្ថាប័នរដ្ឋ និង សង្គមស៊ីវិល និងកសាងខ្សែបណ្ដាញក្នុងទំនាក់ទំនងវិជ្ជាជីវៈ និង បញ្ហាការងារក្នុងបរិបទកំណែទម្រង់ច្បាប់និងសង្គម។

### បង្កើនលទ្ធភាពទទួលបានព័ត៌មាន :

សេចក្ដីបង្គាប់អាជ្ញាកណ្ដាលទាំងអស់មានបោះពុម្ពផ្សាយនៅលើវិបសាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និង សៀវភៅកម្រង សេចក្ដីបញ្ជូ និងសេចក្ដីបង្គាប់អាជ្ញាកណ្ដាល។ ស្នាដៃនេះធ្វើឱ្យក្រុមប្រឹក្សានេះក្លាយជាស្ថាប័នតែមួយគត់ក្នុងវិស័យយុត្តិធម៌នៅកម្ពុជាដែលបានបោះពុម្ពផ្សាយនូវរាល់សេចក្ដីសម្រេចប្រកបដោយហេតុផល។ ការណ៍នេះធ្វើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្លាយជាស្ថាប័នជួរមុខ ក្នុងដំណើរការកំណែទម្រង់ច្បាប់នៅកម្ពុជា។ ក្រៅពីនេះនៅមានឯកសារបោះពុម្ពផ្សាយ និងចែកចាយនូវឯកសារព័ត៌មានផ្សេងៗ ជាច្រើនទៀតដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងរបស់ភាគីដែលពាក់ព័ន្ធអំពីសិទ្ធិ និង កាតព្វកិច្ចរបស់ពួកគេ។

*មានតែក្រុមប្រឹក្សាអាជ្ញាកណ្ដាលតែ មួយគត់ដែលចេញសេចក្ដីសម្រេច យ៉ាងស៊ីសង្វាក់ និងប្រកបដោយប្រសិទ្ធិភាព ដោយផ្អែកលើភស្តុតាងដែលភាគីបានបង្ហាញ និង បទបញ្ញត្តិច្បាប់ការងារ ដែលត្រូវយកមកអនុវត្តដោយមិនពិចារណាលើផលប្រយោជន៍ បុគ្គល ឬសមត្ថភាពនៃការចំណាយ ក្រៅផ្លូវការពីសំណាក់ភាគីវិវាទណាមួយ ឡើយ... ។”*

**របាយការណ៍វាយតម្លៃលើផលិតភាពឧស្សាហកម្ម / ពលកម្ម ឆ្នាំ ២00៥ របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)**



ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានបង្ហាញដល់ប្រជាជនកម្ពុជាគ្រប់រូបឱ្យឃើញថា គេអាចដោះស្រាយជម្លោះតាមច្បាប់ នៅក្នុងដំណើរការដែលមានតម្លាភាព យុត្តិធម៌ និងភាពមិនលំអៀងបាន។ ប្រជាជនអាចមានលទ្ធភាពទទួលបានសិទ្ធិរបស់ខ្លួន ហើយមានវេទិកាប្រជាធិបតេយ្យមួយដែលគេអាចធ្វើបណ្ដឹងទាមទារ ហើយបណ្ដឹងទាមទាររបស់ពួកគេពិតជានឹងត្រូវយកមកពិចារណាយ៉ាងយកចិត្តទុកដាក់ដោយអាជ្ញាកណ្ដាលកម្ពុជា ដែលមានគុណសម្បត្តិពេញលេញតាមរយៈសេចក្ដីសម្រេចដែលផ្អែកទៅលើអង្គសេចក្ដីនៃការទាមទារនីមួយៗ និងផ្អែកលើគោលការណ៍សមធម៌ និង យុត្តិធម៌។